**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ១៦៦១ អក
ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌលេខ ០៣០ "ណ"
ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនាថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១
ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**មេធាវីការពារសិទ្ធិជនជាប់ចោទ**

លោក [redacted] មេធាវីការពារសិទ្ធិជនជាប់ចោទ
កញ្ញា មេធាវីការពារសិទ្ធិជនជាប់ចោទ
លោក មេធាវីការពារសិទ្ធិជនជាប់ចោទ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១៦៦១ អ.ក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] **វន** ហៅ **ម៉ាប់** ភេទប្រុស អាយុ ២៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ បើកឡានដឹកដី មានទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្នភូមិដំណាក់សង្កែ សង្កាត់ព្រែកអំបិល ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឌឿន (រស់) ម្ដាយឈ្មោះ [redacted] ម៉ៅ (រស់) ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ **បើកបរដោយធ្វេសប្រហែសបណ្ដាលឱ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅភូមិជ័យជំនះ ឃុំសៀមរាប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

**ការប្រព្រឹត្តរបស់ជនជាប់ចោទខាងលើមានដូចតទៅ ៖**

កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៦ និង ២០នាទី នៅតាមបណ្ដោយផ្លូវជាតិលេខ ២ ស្ថិតក្នុងភូមិជ័យជំនះ ឃុំសៀមរាប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល មានករណីគ្រោះថ្នាក់ចរាចរណ៍ រវាងរថយន្តធន់ដឹកដីចង្កូតស្ដាំ ពាក់ស្លាកលេខ PP0275 បើកបរដោយឈ្មោះ [redacted] វន ដោយបើកកិនឈ្មោះ [redacted] សៀងហៀង បើកបរម៉ូតូម៉ាក HONDA WAVE C110 ពាក់ស្លាកលេខ តាកែវ 1V-2733 បណ្ដាលឱ្យស្លាប់។ នៅថ្ងៃកើតហេតុអ្នកបើកបររថយន្ត និងអ្នកបើកបរម៉ូតូមានទិសដៅស្របគ្នា លុះបើកមកដល់ចំណុចកើតហេតុអ្នកបើកបរម៉ូតូបានវ៉ារថយន្តហើយដួល ក៏បណ្ដាលឱ្យរថយន្តកិនស្លាប់តែម្ដង។



Scanned with CamScanner

_បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ១១៩២ ដក.សស/២០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

_បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ១៨៨៥ ដក.សស/២០ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

_បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ០០៧ ដក.ដស/២០ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល។

_បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះ ០៦២ ដកចត/២១ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល។

## **សារពេលសវនាការ**

១- ជនជាប់ចោទឈ្មោះ [redacted] **វន ហៅ ម៉ាប់** បានឆ្លើយថា: កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ៤ និង ១០នាទី ពេលល្ងាច ខ្ញុំបាទបើកឡានម៉ាកនីសាន់ ពណ៌ស ជាឡានបែនដឹកដី បើកដឹកដីពីឃុំសៀមរាប ចូលមកខេត្តកណ្ដាល តាមបណ្ដោយផ្លូវជាតិលេខ២ ពីត្បូងមកជើង លុះដល់ចំណុចកើតហេតុ (មិនស្គាល់) ស្រាប់តែមានម៉ូតូមួយគ្រឿងម៉ាក វ៉េវ ជិះស្របទិសគ្នាជាមួយឡានខ្ញុំ ហើយបានវ៉ាឡានខ្ញុំពីខាងឆ្វេងដៃ ពេលកំពុងវ៉ាដល់ពាក់កណ្ដាលឡានខ្ញុំ ស្រាប់តែមានកង់បីជិះបញ្រ្ចាសទិសគ្នាទល់មុខម៉ូតូនោះ ស្រាប់តែម៉ូតូនោះដួល ហើយអ្នកជិះម៉ូតូខ្ទាតចូលមកក្រោមឡានខ្ញុំបណ្ដាលឱ្យកង់ឡានកិនអ្នកជិះម៉ូតូស្លាប់ភ្លាមៗ។ ពេលនោះខ្ញុំបានរត់ចេញពីកន្លែងកើតហេតុ ដោយទុកឡាននៅកន្លែងកើតហេតុ ដោយខ្ញុំរត់តាមបណ្ដោយផ្លូវជាតិនោះដើម្បីគេចពីគេវ៉ៃ ហើយក៏មានម៉ូតូមួយគ្រឿងជិះតាមពីក្រោយខ្ញុំ ពេលនោះនគរបាលកំពុងជិះតាមផ្លូវ ខ្ញុំក៏រត់ទៅឱ្យគាត់ជួយ បន្ទាប់មកក៏ឃាត់ខ្លួនខ្ញុំតែម្ដង។

២- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខហាក់** បានឆ្លើយថា: កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ វេលាម៉ោងប្រហែលជាង ៣ រសៀល ខ្ញុំកំពុងនៅផ្ទះ ស្រាប់តែឈ្មោះ[redacted]ហ៊ត ឆាតមកប្រាប់ខ្ញុំថាប្អូនប្រុសរបស់ខ្ញុំមានគ្រោះថ្នាក់ចរាចរណ៍ និងស្លាប់បាត់ហើយ។ ប្រហែលជា ៣៥នាទីក្រោយមក ខ្ញុំបានទៅកន្លែងកើតហេតុ ពេលនោះឃើញសាកសពនៅក្បែរផ្លូវត្រូវបានគេយកក្រណាត់អាវគ្របមុខគាត់ និងពិនិត្យមើលសភាពរាងកាយរបស់ប្អូន ង៉ែត សេងហៀង ឃើញមានឈាមប្រឡាក់ផ្ទៃមុខ និងជាំដើមទ្រូង ចំណែកម៉ូតូ គេលើកបញ្ឈរក្បែរសាកសព ហើយរថយន្តបង្កនៅឆ្ងាយពីម៉ូតូប្រហែល ១៥ ម៉ែត្រ ចតនៅក្បែរផ្លូវ។

៣- សាក្សីឈ្មោះ[redacted] **ផានិត ហៅ ពៅ** បានឆ្លើយថា: កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ ខ្លួនបានអង្គុយផឹកស៊ីនៅខាងមុខតូប ដែលមានចម្ងាយ ២៥ ម៉ែត្រពីកន្លែងកើតហេតុ។ លុះខ្លួនអង្គុយហូបបានមួយសន្ទុះប្រហែលជាកន្លះម៉ោង ខ្ញុំបានឃើញម៉ូតូហុងដា សេ 110 Wave ពណ៌ខ្មៅ ពាក់ស្លាកលេខ តាកែវ 1V-2733 បើកបរក្នុងទិសដៅពីត្បូងមកជើង (តាកែវមកភ្នំពេញ) ពេលមកដល់ចំណុចកើតហេតុខាងលើ ម៉ូតូនោះបានឡើងវ៉ារថយន្តដឹកដី បានផុតបន្តិចក៏គេចជាមួយនឹងម៉ូតូកង់បី (Passapp) ដែលបើកបរក្នុងទិសដៅបញ្រ្ចាសគ្នា (ភ្នំពេញមកតាកែវ) ប៉ុន្តែមិនដឹងថាប៉ះជាមួយកង់បីនោះឬអត់ទេ។ ស្រាប់តែពេលនោះ ខ្ញុំឃើញម៉ូតូជនរងគ្រោះដួលខ្ទាតចេញមកលើផ្លូវចំណែកអ្នកបើកបរម៉ូតូខ្ទាតចូលទៅក្នុងកង់ក្រោយរថយន្តផ្នែកខាងឆ្វេងបណ្ដាលឱ្យស្លាប់បាត់ទៅ។

៤- តំណាងអយ្យការសន្និដ្ឋាន: តាមចម្លើយសារភាពរបស់ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងនានា បញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] **វន ហៅ ម៉ាប់** ពិតជាបានបើកបរដោយធ្វេសប្រហែសបណ្ដាលឱ្យស្លាប់អ្នកដទៃ ដោយឈ្មោះ[redacted]វន បានឆ្លើយថា នៅថ្ងៃកើតហេតុមានម៉ូតូមួយ

គ្រឿងម៉ាករវ៉េរ ជិះស្របទិសគ្នាជាមួយឡានខ្លួន ហើយក៏បានជិះវ៉ាឡានខ្លួន នៅពេលកំពុងវ៉ាដល់ពាក់កណ្តាលឡានស្រាប់តែមានកង់បីជិះមកបញ្ច្រាសទិសគ្នាជាមួយម៉ូតូនោះ ហើយស្រាប់តែម៉ូតូនោះដួលខ្ទាតចូលមកក្រោមឡានខ្លួន បណ្តាលឱ្យកង់ឡានកិនស្លាប់ភ្លាមៗតែម្តង។ ដោយអំពើទាំងនេះ ត្រូវបានច្បាប់កំណត់ថាជាបទ **បើកបរដោយធ្វេសប្រហែសបណ្តាលឱ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅភូមិជ័យជំនះ ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ដូច្នេះ ប្តឹងសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមកំណត់ច្បាប់។

៥- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសន្និដ្ឋានៈ តាមការសួរដេញដោលឃើញថា ជនជាប់ចោទជាកូនក្តីរបស់ខ្ញុំបាទពិតជាបានសារភាពថាបានបើករថយន្តដឹកដីកិនឈ្មោះ [redacted] សេងហៀង បណ្តាលឱ្យស្លាប់ប្រាកដមែន។ ប៉ុន្តែកូនក្តីខ្លួន មិនមានចេតនាទុច្ចរិតក្នុងការបើករថយន្តកិនជនរងគ្រោះឱ្យស្លាប់នោះទេ ហើយក៏មិនបានរត់គេចខ្លួន មិនដោះស្រាយសំណងជូនដល់គ្រួសារនៃសពនោះដែរ ដោយសារតែកូនក្តីរបស់ខ្លួនជាអ្នកស៊ីឈ្នួលដឹកដីឱ្យគេ ដូច្នេះកូនក្តីរបស់ខ្ញុំបាទមិនមានប្រាក់ ទើបហៅបងប្រុស រួមជាមួយថៅកែរថយន្តដឹកដីចេញមុខសងទៅគ្រួសារនៃសពចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក។ មិនត្រឹមតែប៉ុណ្ណោះ គូភាគីក៏ព្រមទទួលប្រាក់នោះ ដោយធ្វើលិខិតប្រគល់-ទទួលប្រាក់ ដែលជាសំណងរដ្ឋប្បវេណី និងព្រមព្រៀងដកពាក្យបណ្តឹងបញ្ចប់រឿងជាមួយឈ្មោះ [redacted] **វន** នៅចំពោះមុខមេធាវី កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ នោះផងដែរ។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

### ក/ អំពីពិរុទ្ធភាព

១- តាមដីកាដំណោះស្រាយលេខ ០០៧ ដក.ដស/២០ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **វន** ហៅ **ម៉ាប់** (អត្តសញ្ញាណខាងលើ) ជាប់ចោទពីបទៈ **បើកបរដោយធ្វេសប្រហែសបណ្តាលឱ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅភូមិជ័យជំនះ ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២- តាមចម្លើយជាប់ចោទឈ្មោះ [redacted] **វន** បង្ហាញឱ្យឃើញថាៈ ជនជាប់ចោទពិតជាបាន បើកបរដោយធ្វេសប្រហែសបណ្តាលឱ្យស្លាប់ជនរងគ្រោះឈ្មោះ ង៉ែត សេងហៀង ប្រាកដមែន។

៣- តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខហាក់** បង្ហាញឱ្យឃើញថាៈ ជនជាប់ចោទឈ្មោះ [redacted] **វន** ពិតជាបានបើកបរដោយធ្វេសប្រហែសបណ្តាលឱ្យស្លាប់ប្អូនប្រុសរបស់ខ្លួនឈ្មោះ [redacted] សេងហៀង ប្រាកដមែន។



Scanned with CamScanner

៤- តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ផានិត បង្ហាញឱ្យឃើញថា: ជនរងគ្រោះពិតជាបានឡើងរ៉ារថយន្តដឹកដី បានផុតបន្តិចក៏គេចជាមួយនឹងម៉ូតូកង់បី ហើយដួលខ្ទាតចេញមកលើផ្លូវចំណែកអ្នកបើកបរម៉ូតូខ្ទាតចូលទៅក្នុងកង់ក្រោយរថយន្តផ្នែកខាងឆ្វេងបណ្តាលឱ្យស្លាប់បាត់ទៅ។

៥- តាមរបាយការណ៍សរុបរបស់ ១០/០២០ របក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ របស់ស្នងការដ្ឋាននគរបាលខេត្តកណ្តាល អធិការដ្ឋាននគរបាលស្រុកកណ្តាលស្ទឹង ឃើញថា: ករណីនេះបង្កឡើងដោយអ្នកបើកបរម៉ូតូ ដោយបើកបរជែងខ្វះការប្រុងប្រយ័ត្នដួលខ្ទាតចូលកង់ក្រោយរថយន្ត ប្រាកដមែន។

៦- តំណាងអយ្យការសន្និដ្ឋាន: តាមចម្លើយសារភាពរបស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងនានា បញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] **វន** ហៅ **ម៉ាប់** ពិតជាបានបើកបរដោយធ្វេសប្រហែសបណ្តាលឱ្យស្លាប់អ្នកដទៃ ដោយឈ្មោះ [redacted] **វន** បានឆ្លើយថា នៅថ្ងៃកើតហេតុមានម៉ូតូមួយគ្រឿងម៉ាកវេវ ជិះស្របទិសគ្នាជាមួយឡានខ្លួន ហើយក៏បានជិះរ៉ាឡានខ្លួន នៅពេលកំពុងរ៉ាដល់ពាក់កណ្តាលឡានស្រាប់តែមានកង់បីជិះមកបញ្ច្រាសទិសគ្នាជាមួយម៉ូតូនោះ ហើយស្រាប់តែម៉ូតូនោះដួលខ្ទាតចូលមកក្រោមឡានខ្លួន បណ្តាលឱ្យកង់ឡានកិនស្លាប់ភ្លាមៗតែម្តង។ ដោយអំពើទាំងនេះ ត្រូវបានច្បាប់កំណត់ថាជាបទ **បើកបរដោយធ្វេសប្រហែសបណ្តាលឱ្យស្លាប់អ្នកដទៃ** ប្រព្រឹត្តនៅភូមិជ័យជំនះ ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ដូច្នេះ ប្តឹងសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមកំណត់ច្បាប់។

៧- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសន្និដ្ឋាន: តាមការសួរដេញដោលឃើញថា ជនជាប់ចោទជាកូនក្តីរបស់ខ្ញុំបាទពិតជាបានសារភាពថាបានបើករថយន្តដឹកដីកិនឈ្មោះ ង៉េត សេងហៀង បណ្តាលឱ្យស្លាប់ប្រាកដមែន។ ប៉ុន្តែកូនក្តីខ្លួន មិនមានចេតនាទុច្ចរិតក្នុងការបើករថយន្តកិនជនរងគ្រោះឱ្យស្លាប់នោះទេ ហើយក៏មិនបានរត់គេចខ្លួន មិនដោះស្រាយសំណងជូនដល់គ្រួសារនៃសពនោះដែរ ដោយសារតែកូនក្តីរបស់ខ្លួនជាអ្នកស៊ីឈ្នួលដឹកដីឱ្យគេ ដូច្នេះកូនក្តីរបស់ខ្ញុំបាទមិនមានប្រាក់ ទើបហៅបងប្រុស រួមជាមួយថៅកែរថយន្តដឹកដីចេញមុខសងទៅគ្រួសារនៃសពចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក។ មិនត្រឹមតែប៉ុណ្ណោះ គូភាគីក៏ព្រមទទួលប្រាក់នោះ ដោយធ្វើលិខិតប្រគល់-ទទួលប្រាក់ ដែលជាសំណងរដ្ឋប្បវេណី និងព្រមព្រៀងដកពាក្យបណ្តឹងបញ្ចប់រឿងជាមួយឈ្មោះ [redacted] **វន** នៅចំពោះមុខមេធាវី កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ នោះផងដែរ។

៨- តាមរបាយការណ៍របស់នគរបាលយុត្តិធម៌ និងចម្លើយជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ព្រមទាំងភស្តុតាងនានា មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យឃើញថា កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] **វន** ហៅ **ម៉ាប់** ពិតជាបាន បើកបរដោយធ្វេសប្រហែសបណ្តាលឱ្យស្លាប់អ្នកដទៃប្រាកដមែន ស្របតាមការសន្និដ្ឋានរបស់តំណាងអយ្យការ។

៩- អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **វន** ហៅ **ម៉ាប់** បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គម។

១០- អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **វន** ហៅ **ម៉ាប់** ដែលបានប្រព្រឹត្តមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមមាត្រា ៨៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

១១- មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **វន** ហៅ **ម៉ាប់** ពីបទ: **បើកបរដោយធ្វេសប្រហែសបណ្តាលឱ្យស្លាប់អ្នកដទៃ** ដែលប្រព្រឹត្តនៅភូមិជ័យជំនះ ឃុំសៀមរាប ស្រុក



Scanned with CamScanner

កណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិ ៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

**ខ/ អំពីវត្ថុតាង**

- គ្មាន។

**គ/ អំពីសំណង និងជំងឺចិត្ត**

- គ្មាន។

**ហេតុដូច្នេះ-តុលាការ**

**សម្រេច**

១- ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **វន** ហៅ **ម៉ាប់** (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ ២ (ពីរ) ឆ្នាំ តែទោសនេះអនុវត្តក្នុងរយៈពេលឃុំខ្លួនបណ្ដោះអាសន្ន ហើយទោសដែលនៅសល់ត្រូវព្យួរ។

ពីបទៈ **បើកបរដោយធ្វេសប្រហែសបណ្ដាលឱ្យស្លាប់អ្នកដទៃ** ដែលប្រព្រឹត្តនៅភូមិជ័យជំនះ ឃុំសៀមរាប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិ ៨៥ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **វន** ហៅ **ម៉ាប់** និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខហាក់**។

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

[redacted] [redacted]

បានឃើញ

...............................

**តំណាងអយ្យការ**

[redacted]

ព្រះរាជអាជ្ញារង

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃទី..១៦..ខែកុម្ភៈឆ្នាំ ២០២១.

**ក្រឡាបញ្ជី**

[redacted]